# សិទ្ធទទួលព័ត៌មាន និងអភិបាលកិច្ចល្អ

## វេទិកាពិភាក្សាស្តីពី

## " ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី និងការទទួលព័ត៌មាន "

ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២

# មាតិកា


១. ស្ថានភាពទូទៅនៃការផ្តល់-ទទួលព័ត៌មាននៅប្រទេសកម្ពុជា

២. យន្តការគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជាទាក់ទងនឹងសិទ្ធទទួលព័ត៌មាន

៣. ប្រភេទព័ត៌មានសំខាន់ៗ

៤. ច្បាប់ស្តីពី សិទ្ធទទួលព័ត៌មាននៅកម្ពុជា

៥. តម្លាភាព និងការទទួលបានព័ត៌មាន

៦. អភិបាលកិច្ចល្អ

៧. ទំនាក់ទំនងរវាងសិទ្ធទទួលព័ត៌មាន និងអភិបាលកិច្ចល្អ

៨. សំណូមពរ និងអនុសាសន៍

# ស្ថានភាពទូទៅនៃការផ្តល់ និងទទួលព័ត៌មាននៅកម្ពុជា



# យន្តការគតិយុត្តនៃព្រះរាជាណាចក្រកម្ពុជាទាក់ទងនឹងសិទ្ធិទទួលព័ត៌មាន

☞ សេចក្តីប្រកាសជាសកលស្តីពី សិទ្ធមនុស្ស របស់អង្គការសហប្រជាជាតិ

☞ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (មាត្រា ២២ ថ្មី ៣១ ៣២ ៣៥ ៤០ ៤១ ៥១ ៨៨ ថ្មី ១១១ ថ្មី ១៤៧ សមាជជាតិ )

☞ ក្រមរដ្ឋប្បវេណី

☞ ក្រមនិតិវិធីរដ្ឋប្បវេណី (មាត្រា ៣ (១ ) មាត្រា ១៨៨ (១ ) មាត្រា ២៥៥ (១) មាត្រា ២៥៥ )

☞ ក្រមព្រហ្មទណ្ឌ- មាត្រា ៦៨ មាត្រា ៦៩ មាត្រា ៧០ មាត្រា ៤២៥

☞ ក្រមនិតិវិធីព្រហ្មទណ្ឌ -មាត្រា ៩៦ (៦ ) មាត្រា ១៤៣ មាត្រា ៣៥៩

☞ ច្បាប់ស្តីពីរបបសារព័តិមាន- មាត្រា ២ មាត្រា ៥

☞ ច្បាប់ស្តីពី បណ្ណសារ- មាត្រា ១ មាត្រា ១៣ មាត្រា ១៦

☞ ប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងព័តិមាន ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រុមទទួលបន្ទុក ព័តិមាន រាជធានី ខេត្ត

☞ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់

☞ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

# ប្រភេទព័ត៌មានសំខាន់ៗ

- ច្បាប់ ក្រិត្យ អនុក្រិត្យ សារាចរ គោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ កម្មវិធីជាតិ សេចក្តីណែនាំ ដីកា សេចក្តីសម្រេច និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗផ្សេងៗទៀត ។ល ។
- ការគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិ ការវិនិយោគសម្បទានសេដ្ឋកិច្ច សង្គមកិច្ច
- ថវិកាជាតិ ថវិកាជាតិដែលបានអនុម័តរៀងរាល់ឆ្នាំ ការគ្រងគ្រង និងប្រើប្រាស់ថវិកាជាតិ ចំណូល ចំណាយ ថវិកាប្រជាពលរដ្ឋ ។ល ។
- របាយការណ៍សវនកម្មជាតិ
- ការប្រើប្រាស់ថវិកាជំនួយ ជាតិ និងអន្តរជាតិ
- ការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ និងព័ត៌មានត្រឡប់ និងបណ្តឹងគ្រប់ប្រភេទ
- ផែនការអភិវឌ្ឍឃុំ សង្កាត់ កម្មវិធីវិនិយោគឃុំ សង្កាត់ និងព័ត៌មានសំខាន់ៗផ្សេងៗទៀត
- ឧទា. ពិន្ទុរបស់ប្រទេសកម្ពុជាស្តីពីការផ្តួចផ្តើមបើកចំហព័ត៌មានថវិកាជាតិ ១៥ ពិន្ទុក្នុងចំណោម ៩២ពិន្ទុ

# ច្បាប់ស្ដីពី  សិទ្ធទទួលព័ត៌មាននៅកម្ពុជា

## គោលបំណង

- អោយនិតិបុគ្គលសាធារណៈ និងនិតិបុគ្គលឯកជនបើកចំហរព័តិមាន
- ផ្ដល់សិទ្ធឱ្យប្រជាពលរដ្ឋទទួលសិទ្ធតាមផ្លូវច្បាប់ក្នុងការទទួលព័តិមាន
- ផ្ដល់ភារៈកិច្ចតាមច្បាប់ដល់អង្គភាពនានាដើម្បីអនុវត្ត
- ធ្វើការផ្សព្វផ្សាយព័តិមានពិតប្រាកដជាសាធារណៈ

## គោលដៅ

ដើម្បីទទួលនូវតម្លាភាព គណនេយ្យភាព និងការអភិវឌ្ឍជាតិ

## គោលការណ៍ទូទៅ

- ព័តិមានត្រូវការពារ
- ព័តិមានត្រូវផ្ដល់
- ព័តិមានត្រូវទទួល

**បច្ចុប្បន្នមាន ៩០ ប្រទេសហើយដែលមានច្បាប់នេះ**

# តម្លាភាព និងការទទួលបានព័ត៌មាន

## តម្លាភាព

ផ្នែកសង្គម : រួមចំណែកបង្កើនភាពជឿជាក់ ទំនុកចិត្ត ធ្វើឱ្យមានភាពសុខុដុមនាក្នុងសង្គមជាតិ

ផ្នែកសេដ្ឋកិច្ច : អាចជួយទប់ស្កាត់ កាត់បន្ថយអំពើពុករលួយ ការកេងប្រវ័ញ្ច និងធ្វើឱ្យមានកំណើនសេដ្ឋកិច្ច

ផ្នែកនយោបាយៈ អាចជួយឱ្យមានប្រជាប្រិយ៍ភាព មានជំនឿ សេចក្ដីទុកចិត្ត ទទួលបានការគាំទ្រ និងមាន លិទ្ធប្រជាធិបតេយ្យ និងការគោរពសិទ្ធមនុស្សត្រូវបានលើកកម្ពស់ ។

ផ្នែកអភិបាលកិច្ចៈ អាចជួយឱ្យមានការចូលរួម មានគណនេយ្យភាព ធ្វើឱ្យការឆ្លើយតបប្រកបដោយប្រសិទ្ធភាព សមភាព ដូចជាការផ្ដល់សេវាសាធារណៈប្រកបដោយគុណភាព និងជាពិសេសជួយពង្រឹង ការគោរពច្បាប់ -និតិរដ្ឋ ។



## តម្លាភាព និងការទទួលបានទទួលព័ត៌មាន

### ផលប្រយោជន៍នៃការទទួលបានព័ត៌មាន

- ធ្វើឱ្យលិទ្ធប្រជាធិបតេយ្យមានភាពមាំមួន
- បង្កើនប្រសិទ្ធភាពការគ្រប់គ្រងសាធារណៈ ជាពិសេសការផ្តល់សេវាសាធារណៈ
- បង្កើនការអភិវឌ្ឍជាតិ តាមរយៈការធ្វើវិនិយោគជាតិ និងអន្តរជាតិប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល
- ការទប់ស្កាត់ កាត់បន្ថយ អំពើពុករលួយ

# ច្បាប់និងអនុក្រឹត្យស្តីពីការផ្តល់ និងទទួលព័ត៌មាននៅថ្នាក់ក្រោមជាតិ

- ក្រុមប្រឹក្សា ខេត្ត ស្រុកត្រូវធ្វើអ្វី១ ដែលអាចធ្វើទៅបាន ដើម្បីធានាឱ្យបានថា **សាធារណជនមានលទ្ធភាពទទួលបានព័តិមាន** ដូចជា របៀបវារៈរបស់ក្រុមប្រឹក្សា កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដីការបស់ក្រុមប្រឹក្សា ផែនការអភិវឌ្ឍន៍របស់ ក្រុមប្រឹក្សា និងឯកសារសំខាន់ៗផ្សេងទៀត ( មាត្រា ៤១, ៥១, ៥០, ១៣០ ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)

- ក្រុមប្រឹក្សាឃុំ និងមេភូមិត្រូវធ្វើការផ្សព្វផ្សាយព័តិមានដល់ប្រជាពលរដ្ឋ ឱ្យបានទៀងទាត់អំពី គោលដៅ និងលទ្ធផលសម្រាប់ការផ្តល់ សេវាអាទិភាព...គម្រោងផែនការអភិវឌ្ឍ និងថវិកាឃុំ កិច្ចប្រជុំ... អាចតម្កល់ទុក ជាសាធារណៈ និងចម្លងចែកជូនអង្គការសមាគម និងសាធារណជនសំខាន់ៗ...( មាត្រា ៧០ នៃច្បាប់គ្រប់គ្រង រដ្ឋបាលឃុំ សង្កាត់ និងមាត្រា ២៩, ៣៣ នៃអនុក្រឹត្យលេខ ២២ ក្រុមប្រឹក្សាឃុំ សង្កាត់ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ប្រការ១៣) ។

# ការផ្តល់  និងទទួលព័ត៌មាននៅថ្នាក់ក្រោមជាតិ

- រៀបចំឱ្យមានវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាសាធារណៈ
- ត្រូវរៀបចំក្តារព័តិមាននៅមុខសាលាខេត្ត និងស្រុក  ឃុំ ដែលអាចឱ្យសាធារណជន អាចពិនិត្យមើលព័តិមានបានងាយស្រួល ត្រឹមត្រូវ ពិតប្រាកដ ច្បាស់លាស់ និងទាន់ពេលវេលា
- កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ត្រូវបើកចំហដល់សាធារណជន -កំណត់ហេតុប្រជុំ ត្រូវបង្ហាញជាសាធារណៈ
- ក្រុមប្រឹក្សាឃុំ  និងមេភូមិត្រូវធ្វើការផ្សព្វផ្សាយព័តិមានសំខាន់ និងមានប្រយោជន៍ដល់ប្រជាពលរដ្ឋឱ្យបានច្រើនតាមដែលអាចធ្វើបាន និងទៀងទាត់ ..... ។ល ។







# អភិបាលកិច្ចល្អ



ការ ព្រម
ព្រៀង
គោល
ការ ណ៍
ច្បាប់ នីតិ
រដ្ឋ
ការ ចូ លរួម
អភិ បាល
កិ ច្ច
ល្អ
ប្រ សិ ទ្ធ
ភាព
ប្រ សិ ទ្ធ
ផល
តម្លាភាព
សមភាព សម
ធម៌
ការ ឆ្លើយ
តប
គណនេ យ្យ
ភាព

# ទំនាក់ទំនងរវាងសិទ្ធទទួលព័ត៌មាន និងអភិបាលកិច្ចល្អ

- មានព័ត៌មានគឺមានអំណាច-ការផ្តល់ព័ត៌មានគឺការផ្តល់អំណាច
- ការទទួលបានព័ត៌មានកាន់តែប្រសើរ ធ្វើឱ្យមានការចូលរួមយ៉ាងសកម្ម មានតម្លាភាព មានគណនេយ្យភាព និងមានមូលដ្ឋានដើម្បីធ្វើការសម្រេចចិត្តអ្វីមួយបានសមស្រប ត្រឹមត្រូវ
- ដូច្នេះ សិទ្ធទទួលព័ត៌មាន និងច្បាប់ស្តីពីសិទ្ធទទួលព័ត៌មាន គឺជាមធ្យោបាយយ៉ាងសំខាន់ និងចាំបាច់ដែលត្រូវតែមានដើម្បីពង្រឹងអភិបាលកិច្ចមូលដ្ឋានឱ្យកាន់តែបានល្អប្រសើរ និងរួមចំណែកលើកកម្ពស់អភិបាលកិច្ចល្អ និងគណនេយ្យសង្គម ។
- បង្កើនកិច្ចសហប្រតិបត្តិកាក្នុងភាពជាដៃគូររវាងអ្នកពាក់ព័ន្ធជាពិសេស ផ្នែកឯកជន និងប្រព័ន្ធផ្សព្វផ្សាយនៅគ្រប់លំដាប់ថ្នាក់កាន់តែបានល្អ ក្នុងន័យវិជ្ជមាន ។

# ការសង្កេត និងទ្រឹស្តីនៃការផ្លាស់ប្តូ

- ប្រការសំខាន់គឺត្រូវជំរុញឱ្យប្រជាពលរដ្ឋឋិតនៅចំកណ្តាលនៃដំណើរការ និងវិធីសាស្រ្ត ដើម្បីលើកកម្ពស់សិទ្ធទទួលព័ត៌មាន ការផ្តល់អំណាចឱ្យស្រ្តី ការចូលរួមរបស់ស្រ្តី ឱ្យបានពិតប្រាកដ ប្រកបដោយន័យស្ថាបនា ។

**From awareness & Frustration to Understanding & Positive Engagement**



# សំណូមពរ និងអនុសាសន៍

- ការលើកកម្ពស់ស្ត្រី ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ ប្រពៃណី និងក្នុងអភិបាលកិច្ច
- ការផ្លាស់ប្តូ ផ្នត់គំនិត ឥរិយាបទ របស់បុរសក្នុងការផ្តល់ការគាំទ្រ ការលើកទឹកចិត្ត និងផ្តល់ឱកាសពិតប្រាកដ ដល់ស្ត្រី ជាពិសេសផ្តល់សិទ្ធក្នុងការធ្វើសេចក្តីសម្រេចចិត្ត
- បញ្ជ្រាបស្ត្រីនៅក្នុងយន្តការ រចនាសម្ព័ន្ធ ដឹកនាំ គ្រប់គ្រង ឱ្យបានច្រើន និងនិតិវិធីចូលរួមឱ្យមានសមភាព
- ធ្វើការស្វែងយល់ និងកំណត់ព័ត៌មានសំខាន់ៗ ដែលស្ត្រីចង់ដឹង
- បង្កលក្ខណៈឱ្យស្ត្រីចូលរួមប្រជុំ វេទិកាឱ្យបានច្រើនតាមដែលអាចធ្វើបាន
- រកវិធីងាយស្រួល ក្នុងការផ្តល់ព័ត៌មានដល់ស្ត្រី តាមរយៈ សារខ្លី សាមញ្ញ មានរូបភាព និងសមស្របតាមកម្រិតយល់ដឹង
- ផ្តល់រង្វាន់ ចំពោះស្ត្រីដែលមានស្នាដៃឆ្នើម




ការគិតតែពីប្រយោជន៍ផ្ទាល់ខ្លួនអាចធ្វើអោយសង្គម
ជាតិមួយរលាយបាន។

LDP